# អយកូដជាតក



*ព្រះសាស្តា កាលស្តេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធ**លោកត្ថចរិយា** (ការប្រព្រឹត្តអំពើជាប្រយោជន៍ដល់សត្វលោក) បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា* **សព្ពាយសំ** *ដូច្នេះជាដើម ។*

*រឿងរ៉ាវ (បច្ចុប្បន្នក្នុងជាតកនេះ) នឹងមានជាក់ច្បាស់ក្នុង* ***មហាកណ្ហជាតក*** *(ទ្វាទសកនិបាត) ឯណោះ ។*

*ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វបដិសន្ធិកើតក្នុងផ្ទៃអគ្គមហេសី របស់ព្រះរាជានោះ ពេលចម្រើនវ័យធំហើយ*

សិក្សាសិល្បសាស្ត្រទាំងពួង កាលព្រះរាជបិតា (សោយទិវង្គត) កន្លងផុតទៅហើយ ក៏បានគ្រប់គ្រងរាជសម្បត្តិ សោយរាជ្យប្រកបដោយធម៌ ។

ក្នុងពេលនោះ មនុស្សទាំងឡាយជាអ្នករាប់អានទេវតា ប្រកាន់ការបូជាទេវតាដោយខុសទំនងថាជាមង្គល (ទេវមង្គលិកៈ) តែងសម្លាប់សត្វទាំងឡាយមានពពែនិងចៀមជាដើមយ៉ាងច្រើន ធ្វើពលិកម្មដល់ទេវតា ។ ព្រះពោធិសត្វបញ្ជាឲ្យពួករាជបុរសត្រាច់វាយស្គរប្រកាសថា ប្រជារាស្ត្រទាំងឡាយចូរឈប់សម្លាប់សត្វ ។ ពួកយក្សកាលមិនបានពលិកម្ម ក៏ក្រោធខឹងនឹងព្រះពោធិសត្វ បាននាំគ្នាទៅកាន់សមាគមយក្សក្នុងព្រៃហិមពាន្ត ហើយបញ្ជូនយក្សដ៏កាចសាហាវមួយឲ្យទៅសម្លាប់ព្រះពោធិសត្វ ។ យក្សនោះកាន់យកញញួរដែកដែលភ្លឺប្រាលរន្ទាលដ៏ធំ ទំហំប៉ុនកំពូលផ្ទះ មកដោយគិតថា យើងវាយសម្លាប់ស្តេចនោះដោយញញួរនេះ ដូច្នេះហើយ ក្នុងចន្លោះមជ្ឈិមយាមនៃរាត្រី ក៏មកឋិតនៅក្បាលដំណេករបស់ព្រះពោធិសត្វ ។

ក្នុងខណៈនោះ អាសនៈរបស់សក្កទេវរាជ សម្តែងអាការៈក្តៅ ។ ស្តេចសក្កៈកាលពិចារណា បានដឹងហេតុនោះ ទ្រង់កាន់យកឥន្ទវជិរាវុធ ហើយទៅឋិតនៅខាងលើយក្សនោះ។ ព្រះពោធិសត្វឃើញយក្ស ហើយសួរថា អ្នកជាអ្វី មកឋិតនៅ រក្សាយើង ឬក៏ចង់សម្លាប់យើង ដូច្នេះកាលនឹងចរចាជាមួយយក្សនោះ ទើបត្រាស់គាថាទី ១ ថា

**សព្ពាយសំ កូដមតិប្បមាណំ, បគ្គយ្ហ យោ តិដ្ឋសិ អន្តលិក្ខេ,**
**រក្ខាយ មេ ត្វំ វិហិតោ នុសជ្ជ, ឧទាហុ មេ ចេតយសេ វធាយ។**

អ្នកណា ឈរកាន់ញញួរដែកទាំងមូលធំហួសប្រមាណ លើអាកាស អ្នកនោះមកឋិតនៅ ដើម្បីរក្សាអញ (ក្នុងថ្ងៃនេះ) ឬព្យាយាមដើម្បីសម្លាប់អញ ។

*ព្រះពោធិសត្វឃើញតែយក្សប៉ុណ្ណោះ ទ្រង់មិនឃើញព្រះឥន្ទ្រឡើយ ។ យក្សដោយភ័យខ្លាចសក្កទេវរាជ ទើបមិនអាចនឹងប្រហារព្រះពោធិសត្វ ។ យក្សនោះស្តាប់ពាក្យព្រះពោធិសត្វហើយ ពោលថា បពិត្រមហារាជ ខ្ញុំមកបិតនៅ មិនមែនដើម្បីរក្សាព្រះអង្គទេ ខ្ញុំមកដោយគិតថា នឹងវាយសម្លាប់ព្រះអង្គដោយញញួរដែកដែលភ្លឺប្រាលរន្ទាលនេះ តែដោយសេចក្តីភ័យខ្លាចព្រះឥន្ទ្រាធិរាជ ទើបមិនអាចនឹងប្រហារព្រះអង្គបាន ដូច្នេះកាលនឹងសម្តែងបំភ្លឺសេចក្តីនោះ ទើបពោលគាថាទី ២ ថា*

ទូតោ អហំ រាជិធ រក្ខសានំ, វធាយ តុយ្ហំ បហិតោហមស្មិ;
ឥន្ទោ ច តំ រក្ខតិ ទេវរាជា, តេនុត្តមង្គំ ន តេ ផាលយាមិ។

*បពិត្រមហារាជ ខ្ញុំព្រះអង្គជាទូតរបស់អារក្សទឹក ខ្ញុំព្រះអង្គត្រូវពួកអារក្សប្រើមកក្នុងទីនេះ ដើម្បីសម្លាប់ព្រះអង្គ តែថា ព្រះឥន្ទ្រជាស្តេចទេវតារក្សាព្រះអង្គ ហេតុនោះ ខ្ញុំព្រះអង្គនឹងបំបែកព្រះសិរ្សរបស់ព្រះអង្គមិនបានទេ ។*

*ព្រះពោធិសត្វស្តាប់ពាក្យនោះហើយ ក៏ត្រាស់ ២ ព្រះគាថាដទៃទៀតថា*

សចេ ច មំ រក្ខតិ ទេវរាជា, ទេវានមិន្ទោ មឃវា សុជម្បតិ;
កាមំ បិសាចា វិនទន្តុ សព្វេ, ន សន្តសេ រក្ខសិយា បជាយ។

*បើទេវរាជ ទេវានមិន្ទ្រ មឃវៈ សុជម្បតិ រក្សានូវអញ ម្នាលបិសាច អារក្សទាំងអស់ ចូរបន្ទឺឡើងតាមសេចក្តីប្រាថ្នាចុះ យ៉ាងអញមិនតក់ស្លុត ចំពោះពួកអារក្សទឹកទេ ។*

កាមំ កន្ទន្តុ កុម្ភណ្ឌា, សព្វេ បំសុបិសាចកា;
នាលំ បិសាចា យុទ្ធាយ, មហាតី សា វិភឹសិកា។

ពួកកុម្ភណ្ឌ និងពួកបិសាចនៅលើគំនរសំរាមទាំងអស់ ចូរកម្ចាត់តាមសេចក្ដីប្រាថ្នាចុះ នៃបិសាច ពួកបិសាចទាំងអស់ មិនអាចដើម្បីច្បាំងនឹងអញបានទេ ការបន្ទាចគួរឲ្យខ្លាចនោះធំណាស់ (តែអញមិនខ្លាចឯងទេ) ។

បណ្ដាបទទាំងនោះ បទថា **រក្ខសិយា បជាយ** បានដល់ សត្វ ពោលគឺអារក្សទឹក អធិប្បាយថា ពួកអារក្សទឹក ។ បទថា **កុម្ភណ្ឌា** បានដល់ យក្សដែលមានពោះធំ មានអង្គជាតប៉ុនក្អម ។ បទថា **បំសុបិសាចកា** បានដល់ បិសាចដែលនៅលើគំនរសំរាម ។ បទថា **ជាលំ** សេចក្ដីថា ឈ្មោះថា បិសាចទាំងឡាយមិនអាចនឹងប្រយុទ្ធជាមួយនឹងយើង ។ បទថា **មហាតី សា វិភឹសិកា** សេចក្ដីថា យក្សទាំងឡាយប្រជុំគ្នា ហើយសម្ដែងការបន្ទាចណា ការបន្ទាចដ៏ធំនោះ ត្រឹមតែជាការសម្ដែងហេតុនៃការភ័យដល់យើង តែយើងមិនខ្លាចឡើយ។

សក្កទេវរាជដេញឲ្យយក្សនោះរត់ទៅហើយ ទ្រង់ឲ្យឱវាទព្រះមហាសត្វ រួចពោលថា បពិត្រមហារាជ សូមព្រះអង្គកុំភ័យឡើយ ចាប់ពីពេលនេះទៅ ខ្ញុំនឹងប្រកបការរក្សាការពារព្រះអង្គ ដូច្នេះហើយ ទ្រង់ក៏យាងទៅកាន់លំនៅរបស់ខ្លួនវិញ ។

ព្រះសាស្ដានាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា

**តទា សក្កោ អនុរុទ្ធោ អហោសិ** សក្កទេវរាជក្នុងកាលនោះបានមកជាអនុរុទ្ធ

**ពារាណសិរាជា អហមេវ អហោសិំ** ចំណែកព្រះបាទពារាណសី គឺ តថាគត ។

អយកូដជាតក ចប់ ។

(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ចតុក្កនិបាត ចូឡកុណាលវគ្គ បិដកលេខ ៥៨ ទំព័រ ២៣៦)
ថ្ងៃ អាទិត្យ ១៥ កើត ខែស្រាពណ៍ ឆ្នាំច សំរិទ្ធិស័ក ច.ស. ១៣៨០ ម.ស. ១៩៤០
ថ្ងៃទី ២៦ ខែ សីហា ព.ស. ២៥៦២ គ.ស.២០១៨
ដោយស.ដ.រ.ថ.